# បទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិសុខ (crime against peace)

បទឧក្រិដ្ឋនេះ អាចត្រូវបានហៅថា ជាបទឈ្លានពាន (aggression)។ បទឧក្រិដ្ឋនេះ មិនមែន បទឧក្រិដ្ឋសង្គ្រាម (war crime) ទេ។ គេប្រើពាក្យ"បទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព" នេះផ្អែកជាដំបូង ក្នុងលក្ខន្តិកៈ(Charter for International Military Tribunal at Nuremburg) ដើម្បីកាត់ទោសមេដឹកនាំ អីត្លែរ ក្រោយសង្គ្រាមលោកលើកទី២។ ចាប់ពីពេលនោះមក អង្គការសហប្រជាជាតិ បានសង្កត់ធ្ងន់លើបទឧក្រិដ្ឋនេះ ទោះបីមានការជំទាស់ពីរដ្ឋលោកខាងលិច ដោយសារនាំឲ្យមានការលំបាក ក្នុងការដាក់បុគ្គលទទួលខុសត្រូវ (individual criminal liability) ដែលជាសមាសភាពនៃរដ្ឋាភិបាល។ នេះបានបង្ហាញបន្ថែម ដោយភាពស្ទាក់ស្ទើរនៃការដាក់បទល្មើសប្រភេទនេះក្នុងលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌសម្រាប់អតីតយូហ្គោស្លាវី (International Criminal Tribunal for Former Yugoslavia: ICTY)។

នៅពេលពិភាក្សាលក្ខន្តិកៈនៃ ICC បទល្មើសនេះ ត្រូវបានដាក់បញ្ចូលដោយប្រើឈ្មោះជា aggression។ មានភាពចម្រូងចម្រាស់ជាច្រើនក្នុងកិច្ចពិភាក្សា ហើយទោះបីជាយ៉ាងនេះក្តី បទល្មើស ត្រូវបានឯកភាពឲ្យដាក់បញ្ចូល ដែលនិយមន័យ ត្រូវបានអនុម័តនាពេលក្រោយ។ ហេតុនេះហើយ នៅក្នុងឯកសារដំបូងស្តីពីធាតុផ្សំនៃបទល្មើសក្នុង ICC (elements of crimes) មិនមាននិយាយអំពី aggression (Roy Gutman, Crimes of War, 2nd Ed., 2007, p.137) ។

**ខ្លឹមសារបន្ថែម៖** អង្គការសហប្រជាជាតិ បានព្រាងសន្ធិសញ្ញា ស្តីពី បទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព (draft code of crime against the peace and security of mankind, 1996) តែមកដល់ពេលនេះ វានៅតែជាសេចក្តីព្រាងនៅឡើយ។